ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកក្កដា ឆ្នាំ២០២៣

នៅក្នុងខែកក្កដា ឆ្នាំ២០២៣នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

១.១.១-បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យ លោក Kim Jung-Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសម រួមនឹងពិធីបំពាក់គ្រឿងឥស្សរិយយស នៅវិមានព្រឹទ្ធសភា។

១.១.២-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងព្រះរាជពិធីវុឌ្ឍិវា ៩កក្កដា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅខេត្តកំពង់ឆ្នាំង។

១.១.៣-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញជួបសំណេះសំណាល ក្តាប់សភាពការណ៍ការងារ និងសាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរ សង្កាត់ទួលស្វាយព្រៃទី១ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង សង្កាត់ស្រះចក ខណ្ឌដូនពេញ សង្កាត់ទៀន ខណ្ឌដង្កោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ និងមន្ត្រី អាជ្ញាធរខណ្ឌព្រែកព្នៅ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

១.១.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៥ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន០៧ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា**

១.២.១-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០៤ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៥០ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

១.៣.១-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីរុក្ខទិវា ៩កក្កដា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅខេត្តកំពង់ឆ្នាំង

-បានអញ្ជើញជាអធិបតីក្នុងពិធីបើកសន្និសីទនៃភាពជាអ្នកដឹកនាំអន្តរជាតិ ស្តីពីសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ នៅរាជធានីភ្នំពេញ

-បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំត្រៀមចេញដំណើរទៅចូលរួមមហាសន្និបាតសភាអាស៊ាន លើកទី៤៤ (AIPA-44) នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **អ៊ុក ដាមរី** សមាជិកគណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ នៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល នៅរាជធានីភ្នំពេញ

-បានអញ្ជើញជាអធិបតីផ្តល់ភ្លើងបូជាសព លោកជំទាវព្រឹទ្ធាចារ្យវប្បធម៌ខ្មែរ **ម៉ិញ កុសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅរាជធានីភ្នំពេញ។

១.៣.២-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងស្រុកកោះធំ ក្រុងសំពៅពូន និងស្រុកស្អាង ខេត្តកណ្តាល

-បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំង និងសួរសុខទុក្ខប្រជាពលរដ្ឋនៅឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ក្នុងឱកាសដែលក្រុមគ្រូពេទ្យបារាំងមកពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋឥតគិតថ្លៃ

-បានចាត់ទីប្រឹក្សាផ្ទាល់របស់ឯកឧត្តមជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន០៦សង្កាត់ ក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល។

១.៣.៣-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០៥ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១០ច្បាប់។

## ២-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១-មុខងារនីតិកម្ម

-បានប្រជុំគណៈកម្មការកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល២០២៤-២០២៦ និងគម្រោងថវិកាប្រចាំឆ្នាំ២០២៤ របស់ព្រឹទ្ធសភា

### ២.២-មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញធ្វើទស្សនកិច្ចការងារ និងសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅខេត្តសៀមរាប

-បានអញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីការអនុវត្តច្បាប់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព នៅខេត្តបន្ទាយមានជ័យ។

### ២.៣-មុខងារតំណាង

-បានទទួលពាក្យបណ្តឹង ចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន០៥ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ ចំនួន០៥ករណី បានទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធ ចំនួន០៣ករណី កំពុងពិនិត្យសិក្សា ចំនួន០១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង ចំនួន០៥ករណី ព្រមទាំងបានទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន០៥ករណី

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីរុក្ខទិវា ៩កក្កដា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅខេត្តកំពង់ឆ្នាំង

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីកាត់ឫសសីមា និងសម្ពោធសមិទ្ធផលនានា និងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសាលាធម្មសភា វត្តតាយ៉ែករង្សី វត្តប្រាសាទរង្សី ខេត្តសៀមរាប

-អញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី១៦ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា និងពិធីបំពាក់គ្រឿងឥស្សរិយយសការពារជាតិជូនអតីតយុទ្ធជនកម្ពុជា និងគ្រួសារអតីតយុទ្ធជន នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមពិធីផ្សព្វផ្សាយខ្លឹមសារសង្ឃប្រកាសអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣០ និងសេចក្តីសម្រេចសង្ឃសន្និបាតមន្ត្រីសង្ឃរាជធានីភ្នំពេញ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចុះពិនិត្យ និងព្យាបាលជំងឺភ្នែក ផ្តល់ឱសថ និងផ្តល់វ៉ែនតា ជូនបងប្អូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ដោយក្រុមវេជ្ជបណ្ឌិតមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល នៃវគ្គបណ្តុះបណ្តាលអ្នកសង្កេតការណ៍របស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ រាជធានី-ខេត្ត តាមប្រព័ន្ធវីដេអូ នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចុះពិនិត្យពីវឌ្ឍនភាព ព្រមទាំងជួយជំរុញតួនាទីសំខាន់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ នៅខេត្តពោធិ៍សាត់

-បានអញ្ជើញចូលរួមប្រជុំសភាពាណិជ្ជកម្ម ស្តីពីភាពលំបាក និងភាពងាយស្រួលរបស់អ្នកប្រកបអាជីវកម្ម លើវិស័យកសិកម្ម កសិឧស្សាហកម្ម ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីស្វែងរកដំណោះស្រាយ និងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងសភាពាណិជ្ជកម្មកម្ពុជា និងនិយ័តករបរធនបាលកិច្ច

-បានអញ្ជើញជាអធិបតីក្នុងពិធីចែកចង្ក្រានសន្សំសំចៃថាមពល ចំនួន៦៣៥ចង្ក្រាន ជូនប្រជាពលរដ្ឋរស់នៅក្នុងឃុំរំលេច ចំនួន៣៦៤គ្រួសារ និងឃុំឬស្សីសាញ់ ចំនួន២៧១គ្រួសារ ខេត្តព្រៃវែង

-បានអញ្ជើញជាអធិបតីក្នុងពិធីចែកចង្ក្រានសន្សំសំចៃ ថាមពល និងធុងចម្រោះទឹកស្អាត ដែលជាអំណោយរបស់ ក្រុមហ៊ុន អ៊ីនត្រាកូ ជូនដល់ប្រជាពលរដ្ឋ ចំនួន៤៦គ្រួសារ ខេត្តស្វាយរៀង

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន០៥លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តកំពង់ស្ពឺ

-បានអញ្ជើញនាំយកទៀនព្រះវស្សា និងទេយ្យទានប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា ចំនួន៧៩វត្ត នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តបាត់ដំបង និងខេត្តព្រៃវែង

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាក-សួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋានឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ជួយប្រជា-ពលរដ្ឋជួបគ្រោះធម្មជាតិ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេសអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នីតិកាលទី៧ នៅរាជធានីនិងតាមបណ្តាខេត្ត ក្រុងនានា ចំនួន២៧២លើក ព្រមទាំងបានអញ្ជើញជាគណៈអធិបតី ក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៩១លើក។

## ២.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិត តំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការកិច្ចការសេដ្ឋកិច្ចអាយប៉ា (WAIPA) នៃមហាសន្និបាតលើកទី៤៤ ដើម្បីពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងសេចក្តីសម្រេចរបស់គណៈកម្មាធិការកិច្ចការសេដ្ឋកិច្ចអាយប៉ា (WAIPA) និងការងាររៀបចំផ្សេងៗ នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមមហាសន្និបាតលើកទី៤៨ នៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងTBILISSI នៃសាធារណរដ្ឋ GÉORGIE

-បានអញ្ជើញចូលរួមសិក្ខាសាលាអន្តរតំបន់ក្រោមប្រធានបទ " ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) សម្រាប់សភាប្រទេសកំពុងអភិវឌ្ឍន៍ " នៅសាធារណរដ្ឋប្រជាមានិតចិន

-បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយលោក Kansuke Otani ជាអតីតសមាជិកសភាប្រចាំខេត្ត ហ៊ីយ៉ូហ្គូ ប្រទេសជប៉ុន បច្ចុប្បន្នជាប្រធាន Japan Asia Exchage Center ដើម្បីជួបពិភាក្សាការងារ ស្តីពីទំនាក់ទំនងទៅអនាគត លើផ្នែកពាណិជ្ជកម្ម ផ្នែកមនុស្សធម៌ និងជំនួយផ្សេងៗថែមទៀតទៅអនាគត

-បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក Kim Jung Nam ប្រធានមូលនិធិ ក្នុងគោលបំណងពិនិត្យអំពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ។៚

ថ្ងៃ ព្ហ ១ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២៣

**ជ. ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

ចម្លងជូន

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
  (ជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ